*CAMBODIAN*

SEATTLE PUBLIC SCHOOLS

# ការកំណត់ពេលវេលាថ្មីនៃការដឹកជញ្ជូនទៅមកសាលារៀនសម្រាប់ឆ្នាំសិក្សា 2009-2010

នៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាសាលារៀននៃថ្ងៃទី 3 ខែមិថុនា ដែលបានកន្លងហួសទៅហើយនេះ, ចាងហ្វាងនៃក្រុមប្រឹក្សាសាលារៀនបានយល់ព្រមធ្វើការបោះឆ្នោតសម្រេចជាចុងក្រោយ អំពីការកំណត់ពេលវេលាថ្មីនៃការដឹកជញ្ជូនទៅមកសាលារៀនសម្រាប់ឆ្នាំសិក្សា 2009-2010 ដែលនោះនិងត្រូវប្តូរផ្លាស់នៃពេលវេលាថ្មីនៃការដឹកជញ្ជូនទៅមកសាលារៀនសម្រាប់សាលារៀនទូទាំងមណ្ឌល។

គម្រោងការណ៏នេះគឺបានឆ្លើយតបនៅក្នុងគោលការណ៏ថ្មីនៃការបំរើយានជំនិះសម្រាប់មណ្ឌល ដែលបានយល់ព្រមមកពីក្រុមប្រឹក្សាសាលារៀននៅថ្ងៃទី 18 ខែមិនា ដែលបានកន្លងហួសទៅហើយនេះ។ យើងបានស្តាប់យោបល់មកពីក្រុមគ្រួសារទាំងឡាយ ដែលពួកគេស្នើសុំឱ្យមានការកំណត់ពេលវេលាចូលរៀននៅក្រោយថ្ងៃរះ ដើម្បីឱ្យសិស្សានុសិស្សទាំងឡាយដែលរៀននៅសាលារៀនបឋមសិក្សា មានពេលវេលាគ្រប់គ្រាន់សម្រាប់ការដឹកជញ្ជូនទៅមកសាលារៀននៅក្រោយថ្ងៃរះហើយនិងពេលមុនថ្ងៃរៀបលិចសម្រាប់សកម្មភាពផ្សេងៗដែលមាននៅក្រៅផ្ទះ (ដែលសមស្រមទៅតាមពេលវេលាមុនព្រះអាទិត្យអស្តង្គត)។ អាស្រយ៏ទៅលើការឆ្លើយតបទាំងអស់នោះហើយ ទើបយើងធ្វើការសម្រេចផ្លាស់ប្តូរគម្រោងការណ៏នៃពេលវេលាចូលរៀនសម្រាប់សាលារៀនទាំងឡាយឱ្យមានរយះពេលពី 10-15 នាទីបន្ថែមទៀតមុនពេលសិស្សានុសិស្សចូលរៀន។

កម្មវិធីប្តូរផ្លាស់ផ្សេងៗនៅក្នុងការបំរើនៃការដឹកជញ្ជូននិងត្រូវយកជាគំរូនោះ: និងត្រូវកាត់បន្ថយនៅពេលវេលានៃការជិះរថយន្តសម្រាប់សិស្សានុសិស្សជាច្រើន, ដើម្បីផ្តល់ឱ្យមានការទៀងទាត់ពេលវេលានៃការទៅមកសាលារៀនតាមការកំណត់ពេលរបស់សិស្សានុសិស្ស, ហើយដើម្បីបន្ថែមនៅភាពងាយស្រួលសម្រាប់អ្នកបើកបរតាមផ្លូវនិមួយៗផងដែរ។។ ការប្តូផ្លាស់នេះមានន័យថាសាលារៀនសាធារណះក្រុងស៊ីអាថល់និងមានរថយន្តតិចតួចចំនួន 49 រថយន្តក្នុងពេលចាប់ផ្តើមដំណើរការ ដែលប្រមាណទៅនិងចំនួនសិស្សានុសិស្សដែលមាន, ដើម្បីសន្សំការចំណាយផ្សេងៗនៅក្នុងការប្រើប្រេងឥន្ទះហើយនិងក៏ដូចជាការកាត់បន្ថយឧស្មនំពុល, ដូចដែលមណ្ឌលកំពុងសន្សំសំចៃប្រមាណ $2.2 មីលានក្នុងមួយឆ្នាំដែលចំណាយទៅក្នុងតម្លៃនៃការដឹកជញ្ជូននេះផងដែរ។

យើងយល់ថាការប្តូរផ្លាស់ពេលវេលាផ្សេងៗនៃការចូលរៀនហើយនិងចេញពីរៀនទាំងអស់នេះ និងត្រូវសម្របសម្រួលទៅតាមការកំណត់ពេលវេលាផ្សេងៗសំរាប់ក្រុមគ្រួសាររបស់យើងទាំងអស់ ហើយនិងបុគ្គលិកផងដែរ, ហេតុនេះហើយបានជាយើងប្រាប់ដំណឹងនេះទុកជាមុន មុននិងការកំណត់ពេលវេលាថ្មីនៃការចូលរៀនហើយនិងការចេញពីរៀន ដែលនិងត្រូវចាប់ផ្តើមអនុវត្តឡើងនៅក្នុងខែកញ្ញាឆ្នាំ 2009 ខាងមុខនេះ។

ខាងក្រោមនេះគឺជាតារាងពេលវេលាថ្មីនៃការចូលរៀនហើយនិងការចេញពីរៀនសម្រាប់សាលារៀនរបស់យើង ជាមួយនិងពត៌មាននៃពេលវេលាពេលព្រឹកហើយនិងពេលវេលាពេលថ្ងៃត្រង់សម្រាប់ការដឹកជញ្ជូនទៅមកសាលារៀនរបស់រថយន្តផងដែរ។ ពត៌មានច្បាស់លាស់នៃការដឹកជញ្ជូនទៅមកសាលារៀននេះ ការិយាលយ៏យានជំនិះសាលារៀនសាធារណះក្រុងស៊ីអាថល់និងផ្ញើទៅឱ្យក្រុមគ្រួសារនៅក្នុងពាក់កណ្តាលខែសីហាខាងមុខនេះ។

http://www.seattleschools.org/area/transportation/times/proposedtranstimes.pdf